# មជ្ឈមណ្ឌលឯកសារកម្ពុជាចែកសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហមដល់កូនសិស្ស


***ម៉ែខឹល សាលីបា***

***ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ឌី សុជាតា*


*នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយសៀវភៅ ដែលនិយាយអំពីសម័យខ្មែរក្រហមដល់សិស្សវិទ្យាល័យ នៅក្នុងស្រុកសំរោងអណ្តែត ខេត្តតាកែវ ។ សៀវភៅ“ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេ្យ”ត្រូវបាននិពន្ធដោយលោក ឌី ខាំបូលី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា សហការណ៍ជាមួយក្រសួងអប់រំ ។ សៀវភៅនេះមានអត្ថន័យសម្រាប់បំរើជាឯកសារបន្ថែមនិងជាជំនួយដល់ការបង្រៀនសិស្សវិទ្យាល័យនៅទូទាំងប្រទេស ។ បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបជាមួយវិទ្យាល័យក្នុងតំបន់នេះដោយនាយកសាលា ក៏ដូចជាប្រធានការិយាល័យអប់រំស្រុកសំរោង ដែរ ។*

*បន្ទាប់ពីការថ្លែងសុន្ទរកថាបើកកម្មវិធី លោក ឌី ខាំបូលី បាននិយាយទៅកាន់សិស្សវិទ្យាល័យដែលចូលរួមជាច្រើន ។ លោក ឌី ខាំបូលី បានផ្តល់ឲ្យសិស្សានុសិស្សនូវសេចក្តីសង្ខេបមួយអំពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប្បតេយ្យ និងបានពន្យល់ពីសារៈសំខាន់នៃសិក្សា និងការយល់ដឹងពីអ្វីដែលកើតឡើងនៅក្នុងរយៈពេលនោះ ។ លោក ខាំបូលី បានរៀបរាប់ពីរបៀបដែលខ្មែរក្រហមជម្លៀសប្រជាជនទាំងអស់ពីទីក្រុង ហើយមកតាំងលំនៅថ្មីនៅតាមជនបទ និងត្រូវបានដាក់ឲ្យធ្វើការតាមវាលស្រែ ។ ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យរស់នៅក្នុងសហករណ៍ ដោយខ្មែរក្រហមបានបំបាត់ចោលនូវកម្មសិទ្ធទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងប្រាក់កាសទាំងអស់ ។ លោក ខាំបូលី បានបន្តទៀតពីរបៀបដែលខ្មែរក្រហមកម្រិតចំពោះថ្នាក់អប់រំ ។ តាមរយៈការវាយតម្លៃដោយក្រសួងអប់រំប្រហែលជា ៨៥ភាគរយនៃអ្នកចេះដឹង ត្រូវបានសម្លាប់នៅក្នុងសម័យនោះ ។ លោក ឌី ខាំបូលី បានប្រៀបធៀបសង្គមកម្ពុជានៅពេលក្រោយសម័យខ្មែរក្រហមទៅនឹងកែវបែក ថាជាសង្គមបែកបាក់មួយ ដែលពិបាកនិងស្តាបនាឡើងវិញ ។*

*លោក ឌី ខាំបូលី បានកត់សម្គាល់បន្ថែមថា មិនមាននរណាម្នាក់នៅក្នុងចំនោមអ្នកចូលរួមនៅទីនោះ ធ្លាប់បានរស់នៅក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យទេ ប៉ុន្តែ ឪពុកម្តាយ និងយាយតារបស់គេទទួលរងភាពឈឺចាប់នៅក្នុងរយៈកាលនោះ ។ លោក ខាំបូលី អះអាងថា វាកាន់តែមានសារសំខាន់*

ថែមទៀតសម្រាប់សិស្សានុសិស្ស ក្នុងការរៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប្បតេយ្យ ។ គាត់ពន្យល់បន្ថែមថា ក្មេងជំនាន់ក្រោយទាញយកចំណេះដឹងនេះ ដើម្បីកសាងសន្តិភាពសម្រាប់សង្គមកាន់តែខ្លាំងឡើង ។

លោក វ៉ាន់ថាន់ ពៅដារ៉ា ក៏បានផ្តល់នូវសេចក្តីសង្ខេបមួយទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)ដល់សិស្សានុសិស្សដែរ ។ លោក ពៅដារ៉ា ពន្យល់ថា អ.វ.ត.ក ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាសហគមន៍អន្តរជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានជំរុញឲ្យសិស្សានុសិស្សយល់ពីការវិវត្តនៃសាលាក្តីដោយការតាមដាននីតិវិធីរបស់តុលាការតាមរយៈទូរទស្សន៍ ឬកាសែត និងពត៌មានអំពីសាលាក្តី ។

វេទិកានេះ បានឈានដល់ទីបញ្ចប់បន្ទាប់ពីការបង្ហាញជាក្រុមពីសិស្សមួយចំនួនយ៉ាងស្វាហាប់ និងសួរសំនួរល្អៗពីសិស្សានុសិស្ស ។ សិស្សម្នាក់បានសួរមកកាន់ក្រុមការងារអំពីរបៀបដែលតុលាការអាចជួយដល់ជនរងគ្រោះបែបណា បើបទឧក្រិដ្ឋបានប្រព្រឹត្តរួចរាល់អស់ទៅហើយ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានពន្យល់ថា នោះគឺជាការចូលរួមនៅក្នុងនីតិវិធីនៃការកាត់ទោស និងការទទួលបានឱកាសប្រឈមមុខគ្នាជាមួយ ឌុច ក្នុងការជួយជនរងគ្រោះជាច្រើននៅក្នុងការជួយសម្រួលនីតិវិធីតុលាការ ។ លើសពីនេះទៅទៀត លោកបានបញ្ជាក់ថា ការចូលរួមរបស់ជនរងគ្រោះទាំងនោះ គឺដូចជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមានសិទ្ធទទួលបានសំណងសមូហភាព និងសំណងជានិមិត្តរូប ។ សិស្សផ្សេងទៀតបានសួរថា ហេតុអ្វីបានជា ឌុច មិនទទួលការកាត់ទោសដូចជា សាដាម ហ៊ូសេន ដែរ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បញ្ជាក់ថា តុលាការមិនទាន់ផ្តន្ទាទោស ឬក៏កំនត់ទោស ឌុច នៅឡើយទេ ។ លោកក៏បានពន្យល់លម្អិតបន្ថែមទៀតថា វាមិនដូចជានៅប្រទេស អ៊ីរ៉ាក់ នោះទេ ព្រោះច្បាប់អន្តរជាតិ និងច្បាប់នៅកម្ពុជា មិនអនុញ្ញាតឲ្យមានការកាត់ទោសប្រហារជីវិតនោះឡើយ ។

បន្ទាប់ពីការនិយាយជាមួយសិស្សជាបុគ្គល នៅទីបញ្ចប់នៃការធ្វើបទបង្ហាញបានសបញ្ជាក់ឲ្យឃើញពីជោគជ័យចម្បងមួយ ។ សិស្សជាច្រើនបានកត់សម្គាល់ឃើញថា ពួកគេធ្លាប់តែបានឮរបបខ្មែរក្រហមពីឪពុកម្តាយប៉ុណ្ណោះ ប៉ុន្តែពួកគេមានការរំជួលចិត្តក្នុងការទទួលបានសៀវភៅថ្មី និងសម្តែងនូវអារម្មណ៍យកចិត្តទុកដាក់នៅក្នុងការសិក្សាបន្ថែមទៀតពីប្រវត្តិសាស្ត្ររបស់ខ្លួន ។

ព្រឹត្តិការណ៍នេះមានវត្តមានពីអ្នកតំណាង ដែលអញ្ជើញមកពីវិទ្យាល័យទាំង១៣ ក្នុងស្រុកសំរោង ។ អ្នកតំណាងម្នាក់ៗទទួលបានសៀវភៅដូចជាសិស្សានុសស្សិដែរ ។ តាមរយៈការខិតខំប្រឹងប្រែងផ្តល់ផ្សព្វផ្សាយដល់សាធារណៈជននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយសៀវភៅជិត

ពាក់កណ្ដាល ៣០០.០០០ក្បាល នៃសៀវភៅដែលបោះពុម្ពហើយនៅក្នុងឆ្នាំនេះ ។ ផ្អែកលើព័ត៌មានផ្ដល់មកវិញយ៉ាងជាក់លាក់ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានតាមគំរោងនឹងបោះពុម្ពបន្ថែមចំនួន ៧០០.០០០ក្បាលនៅឆ្នាំក្រោយ ។